តុលាការខេត្ត
សៀមរាប-ឧត្តរមានជ័យ

សាលក្រម
លេខ ៣៥ ក ចុះថ្ងៃទី ២០
ខែ មីនា ឆ្នាំ ២០០៦

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៥៤៧ ចុះថ្ងៃទី ១០
ខែ កញ្ញា ឆ្នាំ ២០០៥

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ នាថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦ ដោយមានសមាសភាព :

**ចៅក្រមជំនុំជំរះ**

លោក អៀង គីមថុល ចៅក្រមតុលាការខេត្ត

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្ត

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការខេត្ត

ដើម្បីជំនុំជំរះរឿងព្រហ្មទណ្ឌលេខ ៥៤៧ ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៥ ដែលមានជនជាប់ចោទ :

-ឈ្មោះ **រ ៣** ភេទប្រុស **អាយុ ២២ឆ្នាំ** ជនជាតិខ្មែរ កើតនៅភូមិតាសែង ឃុំស្នួល ស្រុកក្រឡាញ់ ខេត្តសៀមរាប សាសនាព្រះពុទ្ធ កំរិតវប្បធម៌មិនចេះអក្សរ ទីលំនៅមុនពេលចាប់ខ្លួននៅភូមិតាសែង ឃុំស្នួល ស្រុកក្រឡាញ់ ខេត្តសៀមរាប របររកស៊ីធ្វើស្រែ នៅលីវ ។ ឪពុកឈ្មោះ **រ រ** (ស) ម្តាយឈ្មោះ **រ ឃ** (រ) ទោសពីមុន *គ្មាន* ។

ឃុំខ្លួនថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៥ ។

ត្រូវចោទពីបទ **ប៉ុនប៉ងរំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅភូមិតាសែង ឃុំស្នួល ស្រុកក្រឡាញ់ ខេត្តសៀមរាប កាលពីថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៥ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ។

-មានលោក [redacted] **តារា** ជាអ្នកការពារសិទ្ធិជនជាប់ចោទឈ្មោះ **រ ៣** ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ឆ អ** ភេទប្រុស អាយុ ៣៤ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ មានទីលំនៅភូមិតាសែង ឃុំស្នួល ស្រុកក្រឡាញ់ ខេត្តសៀមរាប ។

-លោក [redacted] **ស៊ុន** ជាមេធាវីការពារក្តីអោយជនរងគ្រោះ និង ដើមបណ្តឹងរដ្ឋប្បវេណី ។

*សាលក្រមនេះចូលជាស្ថាពរនៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៦*
*ដោយពុំមានគូភាគីណាមួយចូលមកប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ឡើយ ។*
*សៀមរាប,ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៦*
**ក្រឡាបញ្ជី**
**ហត្ថលេខា និងត្រា**
[redacted]

## ការប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ

កាលពីថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៥ វេលាម៉ោង ១០ព្រឹកឈ្មោះ រ ពា ភេទប្រុស បានទៅឃ្វាលគោនៅគោកតាជាយនៅខាងកើតឈៀងខាងត្បូងត្រពាំងកញ្ជាន់តាគុ ចម្ងាយប្រហែល ១០០ម៉ែត្រ ។ ចំណែកឈ្មោះ ឆ អ និងឈ្មោះ ម ច បានទៅវាយលុបសត្វនៅខាងជើងត្រពាំងតាគុចម្ងាយប្រហែល ២០០ម៉ែត្របានឃើញក្មួយរបស់ខ្លួនឈ្មោះ ស ចណា ភេទស្រី អាយុ ១២ឆ្នាំ ជាមនុស្សមានស្មារតីមិនគ្រប់គ្រាន់នៅអង្គុយក្រោមដើមក្រសាំងស្លៀកសារុងវិត និង មានកាន់កូនកាំបិតចិតបន្លែនៅខាងលិចត្រពាំងតាគុ ។ ពេលនោះឈ្មោះ ឆ អ បានឃើញ រ ពា ដើរចូលទៅចាប់ទាញដៃនាង ច ណា អូសឆ្ពោះទៅខាងជើងត្រពាំងនៅក្រោមដើមត្នោតឈ្មោះ រ ពា បានចាប់សំរាតសំពត់នាង ច ណា ។ នាង ច ណា រើបំរាស់រួចហើយរត់មកក្រោមដើមក្រសាំងវិញ ពេលនោះឈ្មោះ រ ពា ក៏បានទៅចាប់ទាញដៃយកទៅខាងជើងត្រពាំងរហូតមកដល់គុម្ពឫស្សីម្តងទៀត ។ ឈ្មោះ ឆ អ ឃើញហេតុការណ៍នោះក៏មានការសង្ស័យ ហើយបានប្រើឈ្មោះ ម ច ឱ្យទៅលបមើលឃើញឈ្មោះ រ ពា ចាប់ផ្តួលនាង ច ណា ទៅនឹងដី ហើយបានស្រាតក្រមា និង ខោស្ទីបរបស់វាលុតជង្គង់ទ្រោបពីលើបំរុងរំលោភ តែត្រូវនាង ច ណា ស្រែកខ្លាំងៗ ។ ឈ្មោះ ម ច ក៏បានដើរចេញពីម្ខាងគុម្ពឫស្សីធ្វើអោយឈ្មោះ រ ពា ឃើញក៏ស្ទុះក្រោកឡើងលើកខោ រួចស្លៀកក្រម៉ា ហើយដើរគេចខ្លួនទៅទិសខាងកើត ចំណែកក្មេងស្រីបានស្ទុះក្រោកមកខាងជើងគុម្ពឫស្សី ។ ឈ្មោះ ម ច បានមកប្រាប់ឈ្មោះ ឆ អ ហើយក៏មកប្តឹងសមត្ថកិច្ចតែម្តង ។ ឈ្មោះ រ ពា ត្រូវបានសមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៥ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ រ ពា បានឆ្លើយថា ខ្លួនមិនបានប្រព្រឹត្តដូចបទចោទនោះទេ តែកាលពីថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៥ វេលាម៉ោង ១០ព្រឹក ខ្លួនបានដឹកគោពីរក្បាលយកទៅចងឱ្យស៊ីស្មៅនៅគោកតាជាយ ចម្ងាយប្រហែល ១០០ម៉ែត្រនៅខាងកើតឈៀងខាងត្បូងពីត្រពាំងតាគុ ។ ពេលខ្លួនដើរត្រឡប់មកវិញតាមផ្លូវដល់ត្រពាំងខាងលិចក៏បានឃើញឈ្មោះ ច ណា ជាមនុស្សឆ្កួតកំពុងដើរដកសន្ទូងតាមស្រែគេប្រហែលជា ០៣គុម្ពខ្លួន ក៏ចូលទៅចាប់ដៃវាអូសចេញពីស្រែកុំឱ្យដកទៀតវាស្រែកអេៗ ខ្លួនបានអូសដៃឡើងពីស្រែទៅក្រោមដើមក្រសាំងប្រហែល ០៣ម៉ែត្រពីស្រែនាងរើបំរាស់ នាងសំរាតសំពតនាងទម្លាក់ខ្លួនទៅនឹងទឹក ខ្លួនក៏លែងដៃនាង ខ្លួនដើរទៅផ្ទះខ្លួនឃើញឈ្មោះ អ និង ឈ្មោះ ច ដើរទៅរកនាង ច ណា ។ ឈ្មោះ អ និង ឈ្មោះ ច ជាអ្នកទៅវាយលុបសត្វក្បែរនោះចម្ងាយប្រហែល ៥០ម៉ែត្រនៅខាងលិចត្រពាំងអង្គុយបែរមុខទៅកើត ខ្លួនពុំឃើញនាង ច ណា មានកំបិតទេ នៅថ្ងៃនោះខ្លួនពាក់អាវសដៃវែង ស្លៀកក្រម៉ាពណ៌ខ្មៅលាយសការ៉ូ ពណ៌ស និង ខោទ្រនាប់ក្នុងពណ៌ក្រហម ។

ខ្លួនសុំបដិសេធចម្លើយនៅសមត្ថកិច្ចប៉ូលីស ព្រោះគេថា បើឆ្លើយតាមគេៗនឹងអោយទៅផ្ទះវិញ គេមិនបានវាយធ្វើទារុណកម្មទេ ។ ដោយខ្លួនមិនចេះអក្សរគេមិនបានអានឱ្យស្តាប់ទេ ដោយឱ្យខ្លួនផ្តិតមេដៃតែម្តង ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឆ អ ត្រូវជាឪពុកមាបានឆ្លើយថា ខ្លួនត្រូវជាឪពុកមាឈ្មោះ ស ចណា ដែលជាមនុស្សឆ្កួត និង គទៀតផង ។ នៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៥ វេលាម៉ោង ០៧ព្រឹកនាង ច ណា បានដើរទៅអង្គុយលេងនៅក្រោមដើមក្រសាំងក្បែរត្រពាំងតាគុ ។ ចំណែកខ្លួនបានចេញទៅវាយលុបនៅខាងជើងត្រពាំងគួឆ្ងាយពីត្រពាំងតាគុប្រហែល ២០០ម៉ែត្រ តែខ្លួនបានឃើញនាង ច ណា នៅអង្គុយក្រោមដើមក្រសាំងមានស្លៀកសារុងវិតអត់អាវ ខ្លួននៅក្នុងស៊ុមបែរមុខទៅកើត ។ ចំណែកឈ្មោះ ម ច នៅលើដើមឈើ ខ្លួនមិនបានឃើញនាង ច ណា ចុះទៅក្នុងស្រែទេ ។ នៅវេលានោះខ្លួនបានឃើញឈ្មោះ រ ពា ដើរមកពីកើតតម្រង់មក

ត្រពាំងតាតុមកតាមភ្លឺស្រែ ។ ពេលមកដល់កន្លែងនាង ច ណ អង្គុយក្រោមដើមក្រសាំងវាបានចូលទៅហុចដៃដកយកកាំបិតព្រា រួចហើយបានចាប់ដឹកដៃទាញពីក្រោមដើមក្រសាំងទៅខាងជើងត្រពាំងចម្ងាយប្រហែល ០៥ម៉ែត្រនៅក្រោមដើមត្នោត ខ្លួនបានឃើញឈ្មោះ ព អង្គុយស្រាតសារុង តែនាង ច ណ បានរត់ចេញមកនៅក្រោមដើមក្រសាំងវិញ ខ្លួនបានឃើញឈ្មោះ រ ព ដើរមកដឹកដៃនាង ច ណ យកទៅជើងម្តងទៀតរហូតដល់គុម្ពឬស្សី តែខ្លួនបានបាំងនិងព្រៃរពាក់ ខ្លួនបានហៅឈ្មោះ ម ច ឱ្យចុះពីលើដើមឈើទៅមើល ខ្លួនមិនបានទៅមើលទេ ។ ពេលនោះឈ្មោះ ម ច ត្រឡប់មកវិញបានប្រាប់ខ្លួនថា គេឃើញនាង ច ណ នៅដេកស្រែក ឃើញឈ្មោះ ព លុតជង្គង់នៅពីលើ ។ ពេលនោះឈ្មោះ ម ច ដើរទៅឱ្យឈ្មោះ រ ព ឃើញ។ រ ព បានក្រោកស្លៀកខោ និង កន្សែងរួចដើរទៅកើតចម្ងាយប្រហែល ៤០០ម៉ែត្រ ទៅដល់ស្ទឹងតាសែងក៏បាត់តែម្តង ។ ខ្លួនក៏បានដើរទៅមើលនាង ច ណ នៅអង្គុយក្រោមដើមក្រសាំង តែមិនបានមើលប្រដាប់ភេទនាងទេ ដោយបានត្រឡប់មកផ្ទះវិញប្តឹងសមត្ថកិច្ចតែម្តង ។ នៅក្នុងរឿងនេះខ្លួនប្តឹងទាមទារសំណងជម្ងឺចិត្តចំនួន ២៥០០.០០០រ៉ុ០០ (ពីរលានប្រាំសែនរៀល) ។

-សាក្សីឈ្មោះ ម ច មិនបានចូលមកឆ្លើយទេ ដោយទៅធ្វើការកម្មករនៅប្រទេសថៃ តែបានឆ្លើយនៅសមត្ថកិច្ចនគរបាលស្រុកក្រឡាញ់ថា នៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៥ វេលាម៉ោង ០៧ព្រឹក ខ្លួន និង ឈ្មោះ ឆ អ បាននាំគ្នាទៅវាយលុបសត្វនៅខាងកើតភូមិតាសែងប្រហែល ២០០ម៉ែត្រ ។ ពេលរៀបលុបសត្វហើយ ពួកខ្លួនទាំងពីរនាក់បានត្រឡប់មកហូបបាយនៅផ្ទះវិញ ។ ក្រោយពីហូបបាយរួចហើយ ពួកខ្លួនទាំងពីរនាក់បាននាំគ្នាទៅកន្លែងដាក់លុបសត្វវិញប្រហែលជាម៉ោង ១០ព្រឹក ពេលទៅដល់ខ្លួនឡើងលើចុងឈើចាំមើលសត្វចុះ ។ ចំណែកឈ្មោះ ឆ អ នៅអង្គុយក្នុងស៊ុម ខ្លួនចងក្រម៉ាដេកលក់លើចុងឈើ ស្រាប់តែឈ្មោះ អ បានដាស់ខ្លួនឱ្យជួយមើលអា ព វាធ្វើម៉េចចេះ ។ ពេលនោះខ្លួនមើលទៅឃើញឈ្មោះ ព កាន់សំពត់ និង កាំបិតនៅដៃខាងស្តាំ ដើរចេញពីដើមក្រសាំងទៅគុម្ពឬស្សី ក្បែរមាត់ត្រពាំងខាងលិច ហើយវាបានបោយដៃក្មេងស្រីដែលឆ្អូតកំពុងឈរស្រាត តែក្មេងស្រីនោះមិនទៅទេឈ្មោះ ព បានដើរមកដឹកដៃក្មេងនោះយកទៅគុម្ពឬស្សីវាចាប់ផ្តួលខ្លួនក្មេងស្រីនោះទៅនឹងដី វាក៏ស្រាតក្រម៉ា និង ខោខ្លីពណ៌ក្រហមចាប់ផ្តើមធ្វើសកម្មភាពរំលោភ ពេលនោះខ្លួនបានដើរទៅជិតវាប្រហែល ១០ម៉ែត្រម្ខាងគុម្ពឬស្សី ខ្លួនបានឮក្មេងស្រីស្រែកខ្លាំងពេកខ្លួនបានដើរតម្រង់ឱ្យវាឃើញ ។ ពេលនោះឈ្មោះ ព ឃើញវាក៏ស្ទុះងើបឡើងលើកខោរួចស្លៀកក្រម៉ា ហើយដើរគេចខ្លួនទៅតាមគុម្ពោតព្រៃទៅទិសខាងកើត ចំណែកក្មេងស្រីនោះស្ទុះទាំងស្រាតទៅខាងជើងគុម្ពឬស្សី ខ្លួនបានឈរមើលកន្លែងកើតហេតុប្រហែលជា ០២នាទីខ្លួនក៏ដើរទៅកន្លែងដាក់លុបវិញ ពេលទៅដល់ឈ្មោះ អ បាននាំខ្លួនមកកន្លែងកើតហេតុវិញ ។

## តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា

ឆ្លងតាមការសួរដេញដោលរវាងដើមបណ្តឹងរដ្ឋប្បវេណី អំណានចម្លើយសាក្សី និង ចម្លើយរបស់ជនជាប់ចោទរួចមកឃើញថា ឈ្មោះ រ ព ពិតជាបានប្រព្រឹត្តបទល្មើសប៉ុនប៉ងរំលោភសេពសន្ថវៈទៅលើជនរងគ្រោះឈ្មោះ ស ចណ ដោយបានចូលទៅចាប់ទាញដៃពីក្រោមដើមក្រសាំង យកទៅខាងជើងត្រពាំងនៅក្បែនគុម្ពឬស្សី ដោយផ្តួលទៅនឹងដីបានស្រាតខោទ្រនាប់ពណ៌ក្រហម និង ក្រម៉ាទ្រោបពីលើ តែត្រូវបានឃើញឈ្មោះ ច ដើរទៅជិតក៏ស្ទុះងើបឡើងស្លៀកខោ និង ក្រម៉ា ដើរគេចខ្លួនបាត់ទៅ ។ ហេតុនេះមានពិរុទ្ធភាពធ្ងន់ល្មមលើឈ្មោះ រ ព ពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិតាសែង ឃុំស្ពួល ស្រុកក្រឡាញ់ ខេត្តសៀមរាប កាលពីថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៥ ។

ហេតុនេះសូមតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ២៨៣ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០៦ ទុកជាបានការពេញទាំងមូល ។

សូមតុលាការផ្តន្ទាទោសជនជាប់ចោទតាមបញ្ញត្តិមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ។

លោកមេធាវី **ខឹម សារា** ការពារសិទ្ធិជនជាប់ចោទឈ្មោះ **រ ព** បានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការសួរដេញដោលរួចមកឃើញថា កូនក្តីខ្លួនមិនបានប៉ុនប៉ងរំលោភសេពសន្ថវៈទៅលើកុមារីទេ គឺគ្រាន់តែចូលទៅចាប់ដៃកុំឱ្យក្មេងនោះដកសន្ទូង ហើយនាងបានស្រែក និង រើបំរាស់រហូតដល់ដួល ហើយកូនក្តីខ្លួនបានលែងដៃ ហើយដើរចេញ តែពេលនោះឈ្មោះ ម ច និងឈ្មោះ ឆ អ ឃើញដោយបានចោទថា កូនក្តីខ្លួនបំរុងរំលោភទៅវិញ ហេតុនេះសូមតុលាការមេត្តាប្តូរបទចោទពីប៉ុនប៉ងរំលោភសេពសន្ថវៈទៅជាបទបៀតបៀនកេរ្តិ៍ខ្មាសវិញ ។ ស្អុត?

លោកមេធាវី **ប៉ុល ស៊ុន** ការពារសិទ្ធិជនរងគ្រោះ និង ដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមការសួរដេញដោល និង អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និង សាក្សីរួចមកឃើញថា ឈ្មោះ **រ ព** ពិតជាបានប៉ុនប៉ងរំលោភសេពសន្ថវៈទៅលើជនរងគ្រោះឈ្មោះ **ស ចណ** ដោយបានចូលទៅចាប់ទាញដៃនាងពីក្រោមដើមក្រសាំងអូសទៅជិតគុម្ពឫស្សី ហើយបានផ្តួលនាងទៅនឹងដី រួចឡើងទ្រោបពីលើ តែត្រូវបានឈ្មោះ ច ដើរទៅឱ្យឃើញឈ្មោះ **រ ព** បានក្រោកដើរគេចខ្លួនបាត់ទៅ ហេតុនេះសូមតុលាការមេត្តាពិចារណាអំពីទោសកំហុសដែលគេបានធ្វើមកលើកូនក្តីខ្លួន ដោយយោងតាមរដ្ឋធម្មនុញ្ញ និង សន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ។

ជនជាប់ចោទឈ្មោះ **រ ព** បាននិយាយសំដីចុងក្រោយបង្អស់ថា សូមតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-បានស្តាប់ចម្លើយជនជាប់ចោទ
-បានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
-បានស្តាប់ការអានចម្លើយសាក្សី
-បានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ
-បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ
-បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនរងគ្រោះ
-បានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

## តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ

ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

-កាលពីថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៥ វេលាម៉ោងប្រហែល ១០ព្រឹក ឈ្មោះ **រ ព** បានជួបឈ្មោះ **ស ចណ** អាយុ ១២ឆ្នាំជាមនុស្សឆ្កួតនៅក្រោមដើមក្រសាំងជាទីស្ងាត់ចូលទៅចាប់ទាញដៃយកទៅខាងកើតគុម្ពឫស្សីសំរាតសំពត់ **ចណ** បំរាស់រួចរត់ទៅក្រោមដើមក្រសាំងវិញ **រ ព** ទៅចាប់ដៃអូសទៅកន្លែងដើមវិញ ផ្តួលនាងស្រាតក្រម៉ា និង ខោខ្លីខ្លួនឯងប្រុងរំលោភសេពសន្ថវៈ តែត្រូវឈ្មោះ ម ច ឃើញដើរទៅបង្អើល **រ ព** ក៏បញ្ឈប់សកម្មភាពដើរគេចខ្លួនទៅផ្ទះ ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ ៖ ព មានចែង និង ផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ។

-ប៉ុន្តែបើពិនិត្យឱ្យដិតដល់ទៅឃើញថា ជនជាប់ចោទឈ្មោះ ៖ ព ជាមនុស្សល្ងិតល្ងង់ខ្វះការពិចារណា ហើយទើបប្រព្រឹត្តបទល្មើសជាលើកដំបូង ។

-យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឆ ៖ បានប្តឹងទាមទារសំណងជម្ងឺចិត្តចំនួន ២.៥០០.០០០ រៀល (ពីរលានប្រាំសែនរៀល) តុលាការគប្បីពិចារណាដល់បញ្ហានេះទៅនឹងព្យសនកម្មនៃអំពើល្មើសនេះ ។

## <u>ហេតុដូច្នេះវិនិច្ឆ័យសេចក្តី</u>

១-ផ្តន្ទាទោសឈ្មោះ ៖ ព ដាក់ពន្ធនាគារកំណត់ ១៥ឆ្នាំ ( ដប់ប្រាំឆ្នាំ) គិតពីថ្ងៃឃុំខ្លួន ។

ពីបទ **ប៉ុនប៉ងរំលោភសេពសន្ថវៈ** តាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០២ ប្រព្រឹត្តនៅភូមិតាសែង ឃុំស្នួល ស្រុកក្រឡាញ់ ខេត្តសៀមរាប កាលពីថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៥ ។

២-សំរេចឱ្យឈ្មោះ ៖ ព សងសំណងជម្ងឺចិត្តជាប្រាក់ចំនួន ៥០០.០០០៛០០ ( ប្រាំរយពាន់រៀលគត់) ទៅឱ្យឈ្មោះ ឆ ៖ ជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទាមទារលើសពីនេះលើកចោល ។

ក្នុងករណីគ្មានប្រាក់សងធនទណ្ឌនេះទេ ត្រូវដាក់គុកបង្ខំដល់រូបកាយតាមមាត្រា ៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌតាមច្បាប់ ។

៣-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ កំបាំងមុខជនរងគ្រោះ និង ដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និង ត្រា**
[redacted]

**ចៅក្រមជំនុំជំរះ**
**ហត្ថលេខា និង ត្រា**
[redacted]